សូមជម្រាបសួរ! នេះជាការពិពណ៌នា[...]ទៅលើរដូវវស្សា។
អញ្ចឹងយើងបានដឹងហើយថានៅក្នុងប្រទេសកម្ពុជា រដូវមានពីរ គឺរដូវប្រាំង ហើយនឹងរដូវវស្សា។
ហើយក្នុងការពិពណ៌នានេះ គឺខ្ញុំនឹងនិយាយអំពីរដូវវស្សា។ ហើយការនិយាយនេះ គឺទាក់ទងទៅនឹង
ការចងចាំព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងរដូវវស្សា
ហើយជាអ្វីមួយដែលកើតឡើងចំពោះខ្ញុំផ្ទាល់ពេលដែលខ្ញុំនៅកុមារ នៅក្មេង កាលពីនៅក្មេង។
អញ្ចឹង រដូវវស្សាគឺយើងដឹងហើយថា គឺជារដូវដែលមានភ្លៀងធ្លាក់។
ហើយពេលដែលមានរដូវភ្លៀងធ្លាក់ អាកាសធាតុគឺត្រជាក់
ហើយខ្ញុំតែងតែចាំបានថាខ្ញុំចូលចិត្តរដូវវស្សា ពេលដែលមានភ្លៀងធ្លាក់នៅពេលល្ងាច។
ព្រឹត្តិការណ៍មួយដែលខ្ញុំចងចាំ គឺពេលដែល នៅក្នុងរដូវវស្សា គឺធ្វើឲ្យយើងទទួលទានអាហារឆ្ងាញ់។
អញ្ចឹងគឺពេលដែលអាកាសធាតុត្រជាក់គឺខ្ញុំចូលចិត្តញ៉ាំអាហារដែលមានកម្ដៅ ដូចជាសម្ល [...]
ដូចជាស៊ុប ដូចជាសម្ល ដែលក្ដៅៗ។ អញ្ចឹងខ្ញុំចូលចិត្តសម្លក្ដៅៗ។ ហើយពេលដែលមានភ្លៀងធ្លាក់
ហើយព្រឹត្តិការណ៍មួយគឺរៀងរាល់ពេលដែល ជាទូទៅគឺមានភ្លៀងធ្លាក់ច្រើនណាស់ គឺភ្លៀងធ្លាក់ខ្លាំង
មានទឹកធ្លាក់យ៉ាងខ្លាំង ហើយនៅពេលល្ងាច ជាពិសេសខ្ញុំចូលចិត្តភ្លៀងនៅពេលល្ងាច។
ពេលដែលភ្លៀងនៅពេលល្ងាចគឺ បន្ទាប់ពីយើងរៀបចំអាហារពេលល្ងាចរួច ហើយមានភ្លៀងធ្លាក់
ហើយពេលដែលយើងញ៉ាំអាហារបណ្ដើរ ហើយមានភ្លៀងធ្លាក់បណ្ដើរ
គឺជាពេលមួយដែលខ្ញុំចូលចិត្តមែនទែន។ ហើយគឺនៅក្នុងប្រទេសកម្ពុជា
ជាពិសេសក្នុងគ្រួសារខ្ញុំផ្ទាល់ គ្រួសារខ្ញុំស្ថិតនៅក្នុងជនបទ នៅក្នុងតាមខេត្ត
គឺស្ថិតនៅក្នុងខេត្តកំពង់ចាម ហើយជាខេត្តមួយដែលមានចម្ងាយប្រហែលជា ៣
ម៉ោងពីទីក្រុងភ្នំពេញ បើយើងធ្វើដំណើរ[តាម?] ឡាន [...] ឬក៏ឡានឈ្នួល គឺមានរយៈពេល [...]
ប្រហែលជា ៣ ម៉ោង។ អញ្ចឹងបើយើងជិះតាមឡាន គឺមានរយៈពេលប្រហែលជា ៣ ម៉ោង
ធ្វើដំណើរពីទីក្រុងភ្នំពេញ[...] មកកាន់ផ្ទះខ្ញុំនៅខេត្តកំពង់ចាម។ ហើយខ្ញុំចូលចិត្តរដូវវស្សា
ពេលដែលយើងជួបជុំក្រុមគ្រួសារ ញ៉ាំបាយជុំគ្នានៅពេលល្ងាច
ហើយពេលដែលយើងញ៉ាំបាយជុំគ្នាពេលល្ងាច មានភ្លៀងធ្លាក់បណ្ដើរ ហើយស្ដាប់ភ្លៀង
ហើយមានភ្លៀងធ្លាក់ ហើយអាកាសធាតុត្រជាក់ ហើយខ្ញុំចាំបានថាគឺយើងញ៉ាំបាយ
គឺអង្គុយនៅលើផ្ទះ ហើយ បើកទ្វារ ហើយយើងមើលឃើញភ្លៀង
ហើយយើងអង្គុយនៅ[មុខ?]មាត់ទ្វារហ្នឹង គឺការញ៉ាំបាយគឺយើងអង្គុយនៅលើកន្ទេល
អញ្ចឹងអង្គុយនៅលើកន្ទេល ក្រាលលើក្ដារ ហើយអង្គុយបត់ជើងហើយញ៉ាំបាយជុំគ្នា។ អញ្ចឹងជាទូទៅ
គឺយើងអង្គុយជារង្វង់ អង្គុយជារង្វង់ជុំវិញ ហើយអង្គុយនៅលើកន្ទេល នៅលើក្ដារ នៅលើផ្ទះ
ហើយយើងស្ដាប់សូរភ្លៀង។ ហើយសម្លដែលខ្ញុំចូលចិត្តជាងគេគឺសម្លម្ជូរ ហើយខ្ញុំចូលចិត្តណាស់
ពេលដែលញ៉ាំបាយក្ដៅៗ សម្លក្ដៅៗ ហើយមានភ្លៀងធ្លាក់បណ្ដើរ គឺជាអ្វីមួយដែលខ្ញុំចូលចិត្ត។
ហើយខ្ញុំចូលចិត្តសម្លម្ជូបហឹរ ហើយហឹរ ហើយក្ដៅ ហើយមានភ្លៀងធ្លាក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយពេលដែលភ្លៀងធ្លាក់ហ្នឹងគឺភ្លៀងធ្លាក់តក់ៗ មកនៅលើដំបូល ហើយ[...]
សូរសៀងសំឡេងភ្លៀងធ្លាក់បណ្ដើរហើយអាកាសធាតុត្រជាក់ ហើយយើងញ៉ាំសម្ល
ហើយនឹងបានក្ដៅៗជុំគ្នា គឺជាពេលវេលាមួយដែល ធ្វើឲ្យខ្ញុំចងចាំ ហើយជាពេលវេលាមួយ
ដែលខ្ញុំចូលចិត្តចំណាយពេលជាមួយនឹងក្រុមគ្រួសារ ញ៉ាំបាយជុំគ្នាពេលល្ងាច
ហើយយើងអស់គ្នាស្ថិតនៅជុំគ្នា នៅក្នុងដំបូលផ្ទះតែមួយ ញ៉ាំបាយជុំគ្នា មានម្ហូបក្ដៅៗ
ហើយមានភ្លៀងធ្លាក់។ ហើយនេះគឺជាពេលវេលាមួយដែលខ្ញុំចូលចិត្ត
គឺការចំណាយពេលជាមួយនឹងក្រុមគ្រួសារខ្ញុំ។ ហើយខ្ញុំស្រឡាញ់ក្រុមគ្រួសាររបស់ខ្ញុំដែរ។
ហើយខ្ញុំក៏សូមបញ្ចប់ការពិពណ៌នាទៅលើការចងចាំនាពេលកាលពីខ្ញុំនៅតូច
គឺការ[...]ញ៉ាំបាយជុំគ្នាជាមួយក្រុមគ្រួសារ នៅរដូវវស្សា ហើយមានភ្លៀងធ្លាក់បណ្ដើរ
ញ៉ាំបាយជុំគ្នាបណ្ដើរ។ ហើយខ្ញុំក៏សូមបញ្ចប់ការពិពណ៌នានេះដោយប៉ុណ្ណោះដែរ។ សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.